ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
លេខ :.......២៣១.....អ.ជ.ប.ជ.អ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារសម្រួលជួយក្រុមការងារបច្ចេកទេសអន្តរក្រសួងតាក់តែង គោលនយោបាយលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨

## ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩៨៩ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលដំឡើងឋានៈ និងតែងតាំងសមាសភាពថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៩/១៤៧៩ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការដំឡើងឋានៈ តែងតាំង និងផ្តល់ឋានៈដល់ថ្នាក់ដឹកនាំ ទីប្រឹក្សា និងជំនួយការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានឃើញលិខិតលេខ ៩២៧ សជណ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ ស្តីពីការក្រុមការងារបច្ចេកទេសតាក់តែងគោលនយោបាយលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ ២០២៣-២០២៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងការចាំបាច់របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍



អាសយដ្ឋាន : អគារលេខ១៦ ផ្លូវលេខ២៧១ កែង ១៥០ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក ទូរស័ព្ទ (855) 023 882 241 និង ទូរសារ (855) 23 885 129
Tel: (855) 23 882 241 · Fex: (855) 23 885 129 · E-mail: info@naaa.gov.kh · Website: naaa.gov.kh

# **សម្រេច**

**ប្រការ១ ._**

ត្រូវបានបង្កើតក្រុមការងារស្នូល ជួយក្រុមការងារបច្ចេកទេសអន្តរក្រសួងតាក់តែងគោលនយោបាយលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តមវេជ្ជបណ្ឌិត **ហោ ប៊ុនឡេង** | អនុប្រធាន អ.ជ.ប.ជ.អ | ប្រធាន |
| ២. ឯកឧត្តមវេជ្ជបណ្ឌិត **រស់ សីលវ៉ាត់** | អនុប្រធាន អ.ជ.ប.ជ.អ | អនុប្រធាន |
| ៣. ឯកឧត្តមវេជ្ជបណ្ឌិត **តែង គន្ធី** | អនុប្រធាន អ.ជ.ប.ជ.អ | ទីប្រឹក្សា |
| ៤. ឯកឧត្តមវេជ្ជបណ្ឌិត **ឡាន វណ្ណសេង** | ទីប្រឹក្សា អ.ជ.ប.ជ.អ | ទីប្រឹក្សា |
| ៥. លោកជំទាវវេជ្ជបណ្ឌិត **ម៉ារ ផាល័យ** | ទីប្រឹក្សា អ.ជ.ប.ជ.អ | ទីប្រឹក្សា |
| ៦. ឯកឧត្តមបណ្ឌិត **ឈឹម ឃិនដារ៉េត** | អគ្គលេខាធិការ អ.ជ.ប.ជ.អ | អនុប្រធានប្រចាំការ |
| ៧. លោកវេជ្ជបណ្ឌិត **អ៊ុក វិជ្ជា** | ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ | អនុប្រធាន |
| ៨. ឯកឧត្តមវេជ្ជបណ្ឌិត **ស៊ឹម ស៊ូយេង** | អគ្គលេខាធិការរងអ.ជ.ប.ជ.អ | សមាជិក |
| ៩. ឯកឧត្តមវេជ្ជបណ្ឌិត **ឈា សិទ្ធិ** | អគ្គលេខាធិការរងអ.ជ.ប.ជ.អ | សមាជិក |
| ១០. ឯកឧត្តមវេជ្ជបណ្ឌិត **ហេង ហៃ** | អគ្គលេខាធិការរងអ.ជ.ប.ជ.អ | សមាជិក |
| ១១. ឯកឧត្តមបណ្ឌិត **ស៊ឹម សូផៃ** | អគ្គលេខាធិការរងអ.ជ.ប.ជ.អ | សមាជិក |
| ១២. ឯកឧត្តមវេជ្ជបណ្ឌិត **ទេព ណាវុធ** | ប្រធាននាយកដ្ឋាន ផ.ត.វ.ស | សមាជិក |
| ១៣. លោកវេជ្ជ. **វ៉ឹង យ៉ាណាត** | ប្រធាននាយកដ្ឋាន ប.ថ.គ | សមាជិក |
| ១៤. លោកវេជ្ជបណ្ឌិត **ហួត សេរីវង្ស** | ប្រធាននាយកដ្ឋាន ទ.ច.ធ | សមាជិក |
| ១៥. ឯកឧត្តម **ស៊ិន ពិសិដ្ឋ** | ប្រធាននាយកដ្ឋាន រ.ហិ | សមាជិក |
| ១៦. លោកវេជ្ជបណ្ឌិត **សំរិត សុវណ្ណរិទ្ធ** | អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ | សមាជិក |
| ១៧. លោក **អ៊ឹង ប៉ូលីន** | ទីប្រឹក្សាអន្តរាគមន៍យុទ្ធសាស្ត្រ អង្គការ UNAIDS | សមាជិក |
| ១៨. លោក **ជួប សុខចំរើន** | នាយកប្រតិបត្តិអង្គការខាណា | សមាជិក |
| ១៩. លោកវេជ្ជបណ្ឌិត **វិត ស្រេង** | ប្រធានកម្មវិធីអង្គការវ៉ាក់ | សមាជិក |
| ២០. លោកវេជ្ជបណ្ឌិត **សុខ ប៊ុន** | ប្រធានកម្មវិធីអង្គការ CRS | សមាជិក |
| ២១. លោក **ទឹម វ៉ា** | នាយកប្រតិបត្តិអង្គការ HACC | សមាជិក |
| ២២. លោកស្រីវេជ្ជបណ្ឌិត **ហួយ ស៊ីខេង** | ប្រធានកម្មវិធីប្រចាំប្រទេស អង្គការ AHF | សមាជិកា |
| ២៣. លោកស្រី **សេង សុភាព** | នាយកប្រតិបត្តិអង្គការ FHI360 | សមាជិកា |

| | | |
|---|---|---|
| ២៤. លោកស្រី **ហាន សៀងហ៊ន** | នាយិកាប្រតិបត្តិសមាគម អ្នកប្រើប្រាស់ថ្នាំពន្យារជីវិត (AUA) | សមាជិកា |
| ២៥. លោក **សៀម សុផល** | ប្រធានកម្មវិធី CPN+ | សមាជិក |
| ២៦. លោកបណ្ឌិត **ស្រី មុនី** | ទីប្រឹក្សាគោលគម្រោង LHSS | សមាជិក |
| ២៧. លោក **ហ៊ុន ស** | អនុប្រធាននាយកដ្ឋាន ប.ថ.គ | លេខាធិការ |
| ២៨. លោកបណ្ឌិត **ណារិន ពិសិដ្ឋ** | អនុប្រធាននាយកដ្ឋាន ទ.ច.ជ | លេខាធិការ |
| ២៩. លោកវេជ្ជបណ្ឌិត **លី ចាន់ណារ៉ុជ** | អនុប្រធាននាយកដ្ឋាន ផ.ត.វ.ស | លេខាធិការ |

**ប្រការ២ ._**

ក្រុមការងារស្នូល ជួយក្រុមការងារបច្ចេកទេសអន្តរក្រសួងតាក់តែងគោលនយោបាយលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ មានមុខងារ និងភារកិច្ចដូចតទៅ៖

- ប្រមូលឯកសារគតិយុត្ត ពាក់ព័ន្ធនឹងការរៀបចំគោលនយោបាយជាតិលុបបំបាត់អេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨
- សម្របសម្រួលប្រមូលធាតុចូលពីក្រសួង ស្ថាប័នពាក់ព័ន្ធ រាជធានី ខេត្ត ដៃគូជាតិ អន្តរជាតិ និងអង្គការសង្គមស៊ីវិល
- រៀបចំប្រតិទិនការងារ សម្រាប់ការប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួងតាក់តែងគោលនយោបាយលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨
- រៀបចំរបៀបវារៈ ដាក់ជូនក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រជុំ និងពិភាក្សា
- រៀបចំឯកសារពាក់ព័ន្ធ ដើម្បីក្រុមការងារបច្ចេកទេសអន្តរក្រសួង យកជាឯកសារយោងក្នុងការពិភាក្សា
- ធ្វើការវិភាគស្ថានភាពរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍
- ធ្វើការវិភាគស្ថានភាពឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍
- ធ្វើការវិភាគរកមើលគម្លាតនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍
- ធ្វើការកំណត់អាទិភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍
- រៀបចំកម្មវិធីការងារសម្រាប់ដំណើរការតាក់តែងគោលនយោបាយជាតិលុបបំបាត់អេដស៍ឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨
- រៀបចំសេចក្តីព្រាងគោលនយោបាយជាតិលុបបំបាត់អេដស៍ឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ដើម្បីដាក់ជូនក្រុមការងារបច្ចេកទេសអន្តរក្រសួង ពិភាក្សា
- លើកសំណើផែនការសកម្មភាពនៃគោលនយោបាយជាតិលុបបំបាត់ជំងឺអេដស៍ឆ្នាំ២០២៥។

**ប្រការ៣ ._**

- ក្រុមការងារស្នូល ត្រូវកោះប្រជុំ តាមការអញ្ជើញរបស់ប្រធានរបស់ខ្លួន។
- អង្គប្រជុំដំបូងរបស់ក្រុមការងារ ត្រូវអនុម័តនីតិវិធី របៀបរបបប្រជុំតាមសំណើរបស់ប្រធាន។
- របៀបវារៈ និងប្រតិទិនការងាររបស់ក្រុមការងារស្នូល អាចស្នើឡើងដោយប្រធានរបស់ខ្លួន ក្រោយពីបានពិគ្រោះយោបល់ជាមួយអគ្គលេខាធិការ អ.ជ.ប.ជ.អ។

**ប្រការ៤ ._**

ក្រុមការងារស្នូល ត្រូវលើកឡើងជូនក្រុមការងារបច្ចេកទេស នូវគោលការណ៍ និងបទប្បញ្ញត្តិទាំងឡាយជាធរមាន ដែលអាចជួយជាមូលដ្ឋាន សម្រាប់តាក់តែងគោលនយោបាយជាតិ មានជាអាទិ៍៖

- ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) នៅព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា
- លិខិតបទដ្ឋានទាំងឡាយទាក់ទងនឹងការទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍
- ប្រព័ន្ធឆ្លើយតបជាពហុវិស័យចំពោះមេរោគអេដស៍ និងជំងឺអេដស៍
- គោលការណ៍ បី មួយ និង
- ឯកសារ ឬបទដ្ឋានគតិយុត្តឯទៀត តាមការចាំបាច់។

**ប្រការ៥ ._**

អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ច័ន្ទ ១២រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០២២

**ទេសរដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**អៀង_មូលី**

**កន្លែងទទួល** :
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ